ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៧៨៦ សណន.កសក

# សេចក្តីណែនាំ

## ស្តីពី

## វិធានការការពារ ទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក និងព្រៃកោងកាង និងកិច្ចអន្តរាគមន៍សង្គ្រោះត្រីក្នុងរដូវប្រាំងឆ្នាំ២០១៩

យោងតាមសារាចរណែនាំលេខ០២ សរណន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាល ស្តីពីការចាត់វិធានការថែរក្សាទឹកទុក បានបង្ហាញថា នៅដើមឆ្នាំ២០១៩នេះ ព្រះរាជាណាចក្រកម្ពុជានឹងទទួលរងនូវបាតុភូតអែលនីណូ (El Nino) ដែលនឹងបង្កឱ្យអាកាសធាតុនារដូវប្រាំងនេះមានសភាពក្រៅហួតហែង សីតុណ្ហភាពអតិបរមានៅពេលខ្លះអាចហក់ឡើងដល់ ៤០-៤២ °C ។ ស្ថានភាពបែបនេះនឹងងាយបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក និងព្រៃកោងកាង ហើយតាមបណ្តាបឹងព្រែកអាចប្រឈមនឹងការគោក រីងរាក់ ឡើងកំដៅ និងកង្វះអុកស៊ីសែនក្នុងទឹកសម្រាប់ត្រីដកដង្ហើម ជាហេតុបណ្តាលឱ្យត្រីពុលងាប់។

ដើម្បីបញ្ចៀសបាននូវបញ្ហាដែលអាចកើតមានឡើងដោយថាហេតុ ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជាទទួលរងនូវបាតុភូតអែលនីណូនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ត្រូវយកចិត្តទុកដាក់ចាត់វិធានការការពារ ទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក និងព្រៃកោងកាង និងជួយអន្តរាគមន៍សង្គ្រោះត្រីនៅកន្លែងអភិរក្សជាបន្ទាន់ដូចខាងក្រោម៖

១-ទប់ស្កាត់ និងបង្ការការកាប់ឆ្ការដុតរានព្រៃលិចទឹកដើម្បីអភិវឌ្ឍន៍ដំណាំកសិកម្ម ការធ្វើកសិកម្មពនេចរ និងការតាំងទីលំនៅថ្មីដោយវាទយកដីធ្វើជាកម្មសិទ្ធិមិនស្របច្បាប់។

២-ទប់ស្កាត់ការដុតព្រៃលិចទឹកដើម្បីចាប់សត្វ។

៣-ត្រូវរៀបចំជម្រកត្រីដោយប្រើគំន្លោកចងព័ទ្ធដាក់នៅក្នុងអន្លង់ជ្រៅៗ ឬពង្រាយឱ្យបានច្រើនកន្លែងក្នុងកន្លែងអភិរក្សជលផល។

៤-ត្រៀមម៉ាស៊ីនបូមទឹកដើម្បីបូមទឹកទៅលើបរិយាកាសឱ្យធ្លាក់នៅលើបន្ទះក្តារ ដើម្បីបង្កើនអុកស៊ីសែនក្នុងទឹកសម្រាប់ត្រីដកដង្ហើម នៅកន្លែងអភិរក្សជលផល។

៥-ត្រូវការពារឱ្យបានម៉ឺងម៉ាត់នូវសកម្មភាពរបស់ប្រជាពលរដ្ឋចូលធ្វើនេសាទក្នុងកន្លែងអភិរក្សជលផល។

ទទួលបានសេចក្តីណែនាំនេះ រដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ត្រូវសហការឱ្យបានល្អជាមួយនឹងអាជ្ញាធរថ្នាក់ក្រោមជាតិ អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា ដើម្បីអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានជោគជ័យ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ២ រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៩

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

វេង សាខុន

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ឯកសារ កាលប្បវត្តិ